គ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យ
បរធនបាលកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា
Regulate, Supervise, and Develop Trust Sector
in the Kingdom of Cambodia

និយ័តករបរធនបាលកិច្ច
Trust Regulator

លេខ៦៨ ចេញផ្សាយថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២៣
No. 68 Released on February 22, 2023

អត្ថបទប្រចាំសប្តាហ៍ | Weekly Article

# ការវិនិយោគតាមរយៈយន្តការបរធនបាលកិច្ចពាណិជ្ជកម្ម

# Investment Through the Commercial Trust Mechanism



https://www.sec.gov/files/Money-Market-Headerv1.jpg

កាលពីថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៣ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានផ្តល់ការចុះបញ្ជីលើបរធនបាលកិច្ចពាណិជ្ជកម្ម ហ្ស៊ូ យូមីង(សញ្ញាបណ្ណបៃតង) Trust - HSU YU MING Green Bond ដែលត្រូវបានបង្កើតឡើងដោយលោក ហ្ស៊ូ យូមីង ជាបរធនបាលទាយក និងបានជ្រើសរើសយកក្រុមហ៊ុន ហ្គ្រេន កាថេ អ៊ិនវេសមិន ត្រាស់ (ខេមបូឌា) ម.ក ជាបរធនបាល។

តាមរយៈគោលបំណងនៃការបង្កើតបរធនបាលកិច្ចនេះ ទ្រព្យសម្បត្តិបរធនបាលកិច្ច ត្រូវបានវិនិយោគក្នុងសញ្ញាបណ្ណបៃតង ដែលបានធ្វើការចុះបញ្ជីជាផ្លូវការនៅផ្សារមូលបត្រកម្ពុជាដោយជោគជ័យកាលពីថ្ងៃទី១៩ ខែមករា ឆ្នាំ២០២៣ កន្លងទៅនេះ។

សូមបញ្ជាក់ផងដែរថា បរធនបាលកិច្ចនេះ ជាបរធនបាលកិច្ច ស្ថិតក្នុងប្រភេទបរធនបាលកិច្ចពាណិជ្ជកម្ម ដែលត្រូវបានបង្កើតឡើងដោយបរធនបាលទាយក(ជាម្ចាស់ទ្រព្យ) និងផ្ទេរទ្រព្យសម្បត្តិនោះឱ្យទៅបរធនបាល ជាអ្នកគ្រប់គ្រង និងចាត់ចែងវិនិយោគ ដើម្បីជាប្រយោជន៍ដល់អត្ថគាហកៈ ដែលជាបរធនបាលទាយក ឬដល់បុគ្គលដែលជាអ្នកទទួលផលដទៃទៀត ដោយបរធនបាលកិច្ចនោះ ត្រូវបានបង្កើតឡើងដោយមានកម្មវត្ថុស្របច្បាប់ និងមិនផ្ទុយទៅនឹងសណ្តាប់ធ្នាប់សាធារណៈ។

យន្តការបរធនបាលកិច្ចនេះ នឹងជួយជំរុញ និងទាក់ទាញការវិនិយោគទៅក្នុងវិស័យពាក់ព័ន្ធនានា ដូចជាវិស័យមូលបត្រ, វិស័យអចលនទ្រព្យ និងវិស័យពាក់ព័ន្ធផ្សេងទៀត ក៏ដូចជាកាត់បន្ថយហានិភ័យប្រតិបត្តិការ ហើយយន្តការនេះ នឹងជួយបង្កើត និងបង្កើនទំនុកចិត្តនៅក្នុងការវិនិយោគផងដែរ។

On February 21, 2023, the Trust Regulator (TR) provided a commercial trust registration for the Trust - HSU YU MING Green Bond, which was established by Mr. Hsu Ming who is the trustor and has selected Grand Cathay Investment Trust (Cambodia) Plc. as the trustee.

For the purpose of establishing the trust, the trust fund has been invested in the green bond, which were successfully listed on the Cambodia Securities Exchange on January 19, 2023.

Please also note that this trust is a trust belongs to the category of commercial trust which is established by the trustor (the owner of the asset/property) and transfers the assets to the trustee to manage and invest the funds for the benefit of the beneficiary, the trustor, or to any other beneficiary, the trust is established in accordance by laws and not contrary to public order.

This trust mechanism will help promote and attract investment in related sectors such as securities sector, real estate and other related sectors as well as reducing operational risk and this mechanism will also help build and increase investment confidence.

**អត្ថបទ÷ ណង សេរីវុធ | Article: Sereyvuth Nong**

**ឯកសារយោង | References:**

- ច្បាប់ស្តីពីបរធនបាលកិច្ច (២០១៩) និងបទប្បញ្ញត្តិពាក់ព័ន្ធ
- https://www.sec.gov/spotlight/money-market

ប្រកាសបដិសេធ÷ ទស្សនៈនៅក្នុងអត្ថបទនេះជាទស្សនៈរបស់អ្នកនិពន្ធ។ ទស្សនៈនៅក្នុងអត្ថបទនេះមិនមែនជាទស្សនៈរបស់និយ័តករបរធនបាលកិច្ចទេ។
Disclaimer: The opinions expressed in this article are those of the authors. They do not purport to reflect the opinions or views of the Trust Regulator.